ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ ៥២៥១ អពដ

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរំលឹកការបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៦

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនលោកឧកញ៉ា លោកជំទាវ លោក-លោកស្រី ជាអភិបាល ឬ បណ្ណាធិការ នៃសហគ្រាសជាអ្នកជាប់ពន្ធក្នុងរបបស្វ័យប្រកាសទាំងអស់មេត្តាជ្រាបថា អនុលោមតាមច្បាប់ស្តីពីសារពើពន្ធ ការដាក់លិខិតប្រកាសនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៦ ត្រូវផុតកំណត់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ឆាប់ៗខាងមុខនេះ។

គិតត្រឹមថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ នេះ អគ្គនាយកដ្ឋានពន្ធដារសង្កេតឃើញថា សហគ្រាសជាអ្នកជាប់ពន្ធភាគច្រើនបានដាក់លិខិតប្រកាសបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៦រួចរាល់ តាមកាលកំណត់នៃច្បាប់ ខណៈដែលអ្នកជាប់ពន្ធមួយចំនួន នៅមិនទាន់បានមកបំពេញកាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធប្រភេទនេះនៅឡើយ។ ដូច្នេះ ដើម្បីជំរុញការប្រមូលពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៦ ឱ្យបានអស់លទ្ធភាព ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងចៀសវាងនូវការកកស្ទះប្រជ្រៀតគ្នាក្នុងការប្រកាសបង់ពន្ធនៅថ្ងៃជិតផុតកំណត់ដែលអាចនាំទៅដល់បាតុភាពអសកម្មជាយថាហេតុដោយប្រការណាមួយ អគ្គនាយកដ្ឋានពន្ធដារសូមក្រើនរំលឹកចំពោះម្ចាស់សហគ្រាសជាអ្នកជាប់ពន្ធទាំងឡាយដែលពុំទាន់បានបំពេញកាតព្វកិច្ចបង់ពន្ធ មេត្តារួសរាន់អញ្ជើញមកប្រកាសបង់ពន្ធឱ្យបានទាន់ពេលវេលាដូចបានជម្រាបជូនខាងលើ។ ការខកខានមិនបានដាក់លិខិតប្រកាសបង់ពន្ធបានទាន់ពេលវេលា អ្នកជាប់ពន្ធនឹងត្រូវទទួលរងនូវទោសទណ្ឌ តាមច្បាប់ជាធរមាន។

ទន្ទឹមនឹងនេះ ទាក់ទិនទៅនឹងការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូលរយៈពេល ២ ឆ្នាំ សម្រាប់ការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ដែលរាជរដ្ឋាភិបាលបានដាក់ចេញដោយអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ អគ្គនាយកដ្ឋានពន្ធដារសង្កេតឃើញមានការភ័ន្តច្រឡំថាការលើកលែងពន្ធលើប្រាក់ចំណូលនេះ ត្រូវបានអនុវត្តជាទូទៅលើសហគ្រាសធុនតូច និងសហគ្រាសធុនមធ្យមទាំងអស់ ដែលនាំឱ្យសហគ្រាសមួយចំនួនខកខានមិនបានមកបំពេញកាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធប្រចាំខែ ប្រចាំឆ្នាំឡើយ។ អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការបញ្ជាក់ជូនថា ការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូលរយៈពេល ២ ឆ្នាំនេះ ផ្តល់ឱ្យចំពោះតែសហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ដែលបានមកចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ក្នុងអំឡុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ ប៉ុណ្ណោះ។ សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យមទាំងអស់ ទោះបីជាបានឬមិនបានទទួលការលើកទឹកចិត្តនេះក្តី ក៏នៅតែត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសប្រចាំខែ ប្រចាំឆ្នាំ និងកាតព្វកិច្ចសារពើពន្ធផ្សេងទៀតតាមការកំណត់នៃច្បាប់ជាធរមាន។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមនិងជឿជាក់យ៉ាងមុតមាំថា លោកឧកញ៉ា លោកជំទាវ លោក-លោកស្រី ជាអភិបាល ឬ បណ្ណាធិការ នៃសហគ្រាសជាអ្នកជាប់ពន្ធក្នុងរបបស្វ័យប្រកាសទាំងអស់ នឹងយកចិត្តទុកដាក់គោរព និងអនុវត្តកាតព្វកិច្ចសារពើពន្ធស្របតាមការកំណត់របស់ច្បាប់ ប្រកបដោយស្មារតីសហការ និងការទទួលខុសត្រូវខ្ពស់។

**អគ្គនាយកដ្ឋានពន្ធដារ**

**លេខទូរស័ព្ទទំនាក់ទំនង ÷**
០២៣ ៨៨៦ ៧០៨
០១២ ៩៣២ ០៣២
០១០ ៨៥៨ ៨០២